ផ្សារមូលបត្រកម្ពុជា
CSX
ក្រុមហ៊ុន ផ្សារមូលបត្រកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ថ្ងៃ សុក្រ ៦កើត ខែ ពិសាខ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែឧសភា ឆ្នាំ ២០១៩

# សេចក្តីជូនដំណឹង

## សញ្ញាបណ្ណដែលមានការការពារហានិភ័យអត្រាប្តូរប្រាក់ដំបូងគេបំផុតនៅកម្ពុជា បានចុះបញ្ជីនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) មានកិត្តិយសសូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា សញ្ញាបណ្ណសាជីវកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិល អូ អិល ស៊ី ត្រូវបានសម្រេចឱ្យចុះបញ្ជីជាផ្លូវការនៅ ផ.ម.ក ចាប់ពីថ្ងៃទី ១០ ខែឧសភា ឆ្នាំ២០១៩ ខាងមុខនេះតទៅ។ សញ្ញាបណ្ណសាជីវកម្មនេះមានឈ្មោះថា "សញ្ញាបណ្ណសាជីវកម្ម អិល អូ អិល ស៊ី មានការការពារហានិភ័យអត្រាប្តូរប្រាក់" ដែលមានអត្រាគូប៉ុង៨% ក្នុងមួយឆ្នាំ និង "សញ្ញាបណ្ណសាជីវកម្មអិល អូ អិល ស៊ី មិនមានការការពារហានិភ័យអត្រាប្តូរប្រាក់" ដែលមានអត្រាគូប៉ុង ៩% ក្នុងមួយឆ្នាំ។ សញ្ញាបណ្ណនេះមានឥណប្រតិទានរយៈពេល ៣ឆ្នាំគិតចាប់ពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ រហូតដល់ ថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០២២។

សញ្ញាបណ្ណដែលមានការការពារហានិភ័យអត្រាប្តូរប្រាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិល អូ អិល ស៊ី មានលក្ខណៈពិសេសមួយ គឺវាមិនត្រឹមតែផ្តល់នូវអត្រាគូប៉ុងខ្ពស់និងថេរដល់អ្នកកាន់សញ្ញាបណ្ណប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងផ្តល់នូវ**ការការពារហានិភ័យអត្រាប្តូរប្រាក់ដែលអាចកើតមានឡើងនៅពេលអនាគតផងដែរ** ដែលនេះជាសញ្ញាបណ្ណសាជីវកម្មដំបូងគេបំផុតដែលភ្ជាប់នូវលក្ខណៈពិសេសបែបនេះដែលបានចុះបញ្ជីនៅ ផ.ម.ក.។ **នេះគឺជាផលិតផលថ្មីមួយ ដែលអាចជួយទាក់ទាញវិនិយោគិនដែលមានប្រាក់រៀលនិងប្រាក់ដុល្លារអាមេរិក អោយមកវិនិយោគនៅផ្សារមូលបត្រនៅកម្ពុជាបន្ថែមទៀត។**

គួរបញ្ជាក់ថាអិល អូ អិល ស៊ី គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលបានអាជ្ញាបណ្ណប្រកបអាជីវកម្មផ្តល់ប្រាក់កម្ចីនិងទទួលប្រាក់បញ្ញើពីសាធារណជន ដែលស្ថិតក្រោមច្បាប់ និងបទបញ្ញត្តិគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា។ ជាមួយនឹងការិយាល័យចំនួន ៧៧ ទូទាំងព្រះរាជាណាចក្រកម្ពុជា អិល អូ អិល ស៊ី ផ្តល់ជូននូវផលិតផល និងសេវាហិរញ្ញវត្ថុ យ៉ាងសម្បូរបែបដល់អតិថិជនជាច្រើន រួមមានសេវាប្រាក់កម្ចី សេវាប្រាក់បញ្ញើសន្សំ សេវាផ្ទេរប្រាក់ក្នុងស្រុក និងសេវាធនាគារចល័ត ។

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖
**លោក ហៃ លីដេត**
ប្រធានស្តីទីនាយកដ្ឋានចុះបញ្ជីនិងផ្តល់ព័ត៌មាន
អ៊ីម៉ែល៖ lideth.hay@csx.com.kh

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា CSX Cambodia Securities Exchange